ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
11 / 09 / 13
ម៉ោង (Time/Heure): 1000AH
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier:

E218/7/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៣

**ជូនចំពោះ៖** សហមេធាវីនាំមុខ

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង ភាគីទាំងអស់នៃសំណុំរឿង ០០២ និង ផ្នែកគាំពារជនរងគ្រោះ

**កម្មវត្ថុ៖** សេចក្តីសម្រេចជាបន្តបន្ទាប់និងចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពជាក់លាក់ដែលបានធ្វើបច្ចុប្បន្នភាពនៃគម្រោងសំណងជាអាទិភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨១ស្ទួន៤ (E218/7/3)

១. បន្ទាប់ពី អង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សារណៈនៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៣ ដោយស្នើឲ្យសហមេធាវីនាំមុខផ្តល់ព័ត៌មានជាក់លាក់លើគម្រោងសំណងដែលបានស្នើសុំ (ឯកសារ E218/7/2) សហមេធាវីនាំមុខបានដាក់ចម្លើយតបរបស់ខ្លួននៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ (ឯកសារ E218/7/3)។

២. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់នូវព័ត៌មានដែលសហមេធាវីនាំមុខបានដាក់ជូន ហើយធ្វើការសង្កេតដូចខាងក្រោមទាក់ទងទៅនឹងការជូនដំណឹង និងគម្រោងសំណងជាក់លាក់នានានោះ។

**ការសង្កេតទូទៅ**

៣. អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ជាថ្មីម្តងទៀតថា គ្រប់សំណើសុំសំណងទាំងអស់ រួម

បញ្ចូលទាំងគម្រោងសំណងថ្មីនានា ត្រូវដាក់ជូនមកអង្គជំនុំជម្រះសាលាដំបូងយ៉ាងយូរត្រឹម **<u>ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣</u>**។ សហមេធាវីនាំមុខត្រូវធានាថា រាល់សំណួរនិងសេចក្តីណែនាំទាំងអស់ដែលបានចែងនៅក្នុងអនុស្សរណៈ E218/7/2 និងក្នុងអនុស្សរណៈនេះ ត្រូវ**បាន**ដោះស្រាយ ជាពិសេស៖

១) ត្រូវបង្ហាញពីភស្តុតាងនៃការ**យល់ព្រម**និងសហប្រតិបត្តិការរបស់ភាគីទីបីណាមួយ

២) ត្រូវមានការធានាថា មានមូលនិធិពេញលេញ **ពីព្រោះថា** អង្គជំនុំជម្រះសាលាដំបូង មិនអាចធ្វើការយល់ព្រមលើគម្រោងសំណងណាមួយដែលមានការធានាមូលនិធិ តែមួយផ្នែក**នោះ**ទេ

៣) ត្រូវផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូងនូវព័ត៌មានបន្ថែមចាំបាច់នានា ដូចជា សេចក្តីអធិប្បាយលម្អិត (រួមបញ្ចូលទាំងគំរោងប្លង់ និង/ឬ រូបភាព) និងផែនការថវិកាសម្រាប់សំណើទាំងឡាយផងដែរ។

**ការសង្ខេបជាក់លាក់**

***ប្រភេទទីមួយ: ការរំលឹក និងការគោរពវិញ្ញាណក្ខន្ធ***

៤. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា មានតែគម្រោងទីមួយប៉ុណ្ណោះ (ទិវាចងចាំ) បានបំពេញតាមតម្រូវការដែលបានកំណត់។ អង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថាគម្រោងពីរផ្សេងទៀត ដូចដែលបានស្នើឡើងនាពេលបច្ចុប្បន្ននេះ មិនបានបំពេញតាមតម្រូវការដែលបានកំណត់ឱ្យបានពេញលេញទេ ដោយហេតុថា មិនមានមូលនិធិ ឬមានមូលនិធិតែមួយផ្នែកប៉ុណ្ណោះដែលត្រូវបានធានា (គម្រោងទីពីរ និងគម្រោងទីបី)។ លើសពីនេះទៀត ទាក់ទងនឹងគម្រោងទីបី អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា សាលារាជធានីភ្នំពេញមិនទាន់បានសម្រេចឱ្យបានច្បាស់លាស់ពីទីតាំងសមស្របណាមួយនៅឡើយទេ។

***ប្រភេទទីពីរ: ការស្តារនីតិសម្បទា***

៥. ទាក់ទងនឹងសំណើក្នុងប្រភេទទីពីរ (គម្រោងទីបួននិងទីប្រាំ) អង្គជំនុំជម្រះសាលាដំបូងស្នើឱ្យធ្វើការបញ្ជាក់ឱ្យបានច្បាស់ថាតើ ទឹកប្រាក់ចំនួន ១២៥.០០០ អឺរ៉ូ គឺសម្រាប់រយៈពេល ៣៦ខែ នៃគម្រោង ឬចាំបាច់ត្រូវមានមូលនិធិបន្ថែមសម្រាប់រយៈពេលនេះ។ ក្នុងករណីដែលមូលនិធិបន្ថែមគឺជាការចាំបាច់សម្រាប់រយៈពេលទាំងស្រុងនៃគម្រោង អង្គជំនុំជម្រះសាលាដំបូងស្នើឱ្យបង្ហាញពី

ចំនួនមូលនិធិដែលត្រូវការ។ ក្នុងករណីដែលមិនអាចរកមូលនិធិបន្ថែមបាន អង្គជំនុំជម្រះសាលាដំបូងស្នើឱ្យធ្វើការបង្ហាញថាតើគម្រោងទាំងនោះត្រូវការរយៈពេលប៉ុន្មានទៀតដើម្បីបន្ត ដោយផ្អែកលើមូលនិធិដែលបានធានារួចហើយ។

*ប្រភេទទីបី: ការចងក្រងឯកសារ និងការអប់រំ*

៦. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា មូលនិធិនិងការធានាពីអង្គការសម្រាប់អនុវត្តគម្រោងទីប្រាំមួយ (ការតាំងពិពណ៌ជាអចិន្ត្រៃយ៍នៃការបម្លាស់ទីប្រជាជនដោយបង្ខំ) ត្រូវបានធានារួចហើយ។

៧. ទាក់ទងនឹងគម្រោងទីប្រាំពីរ (ការតាំងពិពណ៌ចល័ត) អង្គជំនុំជម្រះសាលាដំបូងនៅមិនទាន់ច្បាស់ថាតើមូលនិធិដែលត្រូវបានធានារួចហើយនោះ គឺជាមូលនិធិតែមួយផ្នែកប៉ុណ្ណោះ ឬចំនួនទឹកប្រាក់ដែលបានបង្ហាញនោះ គ្រប់គ្រាន់សម្រាប់គម្រោងរយៈពេល ២៤ ខែឬទេ។ ក្នុងករណីមូលនិធិបន្ថែមគឺជាការចាំបាច់សម្រាប់រយៈពេលទាំងស្រុងនៃគម្រោង អង្គជំនុំជម្រះសាលាដំបូងស្នើឱ្យបង្ហាញពីចំនួនមូលនិធិដែលត្រូវការ។ ក្នុងករណីដែលមិនអាចរកមូលនិធិបន្ថែមបាន អង្គជំនុំជម្រះសាលាដំបូងស្នើឱ្យធ្វើការបង្ហាញថាតើគម្រោងទាំងនោះត្រូវការរយៈពេលប៉ុន្មានទៀតដើម្បីបន្ត ដោយផ្អែកលើមូលនិធិដែលបានធានារួចហើយ។

៨. ទាក់ទងនឹងគម្រោងទីប្រាំបី (ជំពូកនានានៃសៀវភៅប្រវត្តិសាស្ត្រ) អង្គជំនុំជម្រះសាលាដំបូងសូមរំលឹកដើមបណ្តឹងរដ្ឋប្បវេណីថា អង្គជំនុំជម្រះសាលាដំបូងមិនអាចធ្វើការយល់ព្រមលើជំពូកណាមួយនៃសៀវភៅ ស្តីពីអង្គហេតុណាមួយដែលកំពុងស្ថិតនៅក្រោមការពិចារណារបស់តុលាការ ហើយដែល**នឹង**ត្រូវធ្វើការ**វិនិច្ឆ័យ**ជាចុងក្រោយបានទេ។ **ហេតុដូច្នេះ បើ**ទោះបីជាគំនិតនេះល្អគួរឱ្យកត់សំគាល់ក្តី ក៏អង្គជំនុំជម្រះសាលាដំបូងមិនអាចធ្វើការយល់ព្រមជាផ្លូវការណាមួយលើគម្រោងនេះបានទេ។

៩. តាមខ្លឹមសារដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងសូមណែនាំឲ្យភាគីដាក់សំណើជាលាយលក្ខណ៍អក្សរចុងក្រោយ និងចំណុចជាក់លាក់នានា ជូនមកអង្គជំនុំជម្រះសាលាដំបូងយ៉ាងយូរត្រឹម**ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣**។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងសូមរំលឹកសហមេធាវីនាំមុខថា អង្គជំនុំជម្រះសាលាដំបូងនឹងមិនធ្វើការយល់ព្រមលើសំណើទាំងឡាយណា ដែលមិនអនុវត្តទៅតាមតម្រូវការនានាដូចមានចែងនៅក្នុងអនុស្សារណៈនេះ និងនៅក្នុងអនុស្សារណៈ E218/7/2 ឡើយ។